មន្ទីរពេទ្យ កាល់ម៉ែត
HOPITAL Calmette

## ករុណា ការប្តេជ្ញា ឧត្តមភាព ប្រសិទ្ធភាព ទំនើបកម្ម

# ព្រឹត្តិបត្រសុខភាព មន្ទីរពេទ្យ កាល់ម៉ែត

## Calmette’s Newsletter Nº 05

ខែ មករា ២០១៨ - មីនា ២០១៨

ព្រឹត្តិបត្រលេខ ៥





រៀបចំដោយ
គណៈកម្មការទស្សនាវដ្ដីនៃមន្ទីរពេទ្យកាល់ម៉ែត

# ទំព័រផ្សេងៗ

ខែ មករា ២០១៨ - មីនា ២០១៨

ទស្សនាវដ្តីលេខ ៥

01 ពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់ “**អគារមជ្ឈមណ្ឌលពហុឯកទេស**” នៅមន្ទីរពេទ្យកាល់ម៉ែតនៃកម្ពុជា!

02 “ស្ត្រីរួមគ្នារក្សាសន្តិភាព ដើម្បីអភិវឌ្ឍន៍ជាតិ” **៨មីនា**

03 **បងប្អូនស្ត្រីព្រួយបារម្ភណ៍ ពីគីសដៃស្បូន !**

04 **តើជំងឺដុំមហារីកបំពង់អាហារ អាចមានរោគសញ្ញាអ្វីខ្លះ?**

05 **អាហ្វេរ៉េស៊ីស** (Apheresis)!

06 **ជំងឺលើសឈាម ឬជំងឺលើសសម្ពាធឈាម!**

07 **ទើបតែបាន ៤,៣គីឡូក្រាម វះកាត់បេះដូង!**

08 ជំងឺគ្រោះថ្នាក់សរសៃឈាមខួរក្បាល **អាចបង្ការបាន!**

09 **សំណួរចម្លើយ Quiz?** ទាក់ទងនឹងសុខភាព



# ពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់ “អគារមជ្ឈមណ្ឌលពហុឯកទេស” នៅមន្ទីរពេទ្យកាល់ម៉ែតនៃកម្ពុជា!

ដើម្បីឆ្លើយតបទៅនឹងតម្រូវការសេវាសុខាភិបាលដែលបន្តកើនឡើងជាលំដាប់ពីមួយឆ្នាំ ទៅមួយឆ្នាំ ដែលបង្ហាញតាមរយៈសកម្មភាពប្រចាំថ្ងៃនៃ មន្ទីរពេទ្យទាំងផ្នែកពិគ្រោះជំងឺក្រៅ ផ្នែកសម្រាកពេទ្យគ្រប់ឯកទេសនិងជំនាញ ការពិនិត្យនៅមន្ទីរពិសោធន៍ និងផ្នែករូបភាពវេជ្ជសាស្ត្រ គម្រោង សាងសង់អគារពហុឯកទេស បានលេចជារូបរាងឡើងយ៉ាងពិតប្រាកដ នាថ្ងៃច័ន្ទ ៤រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ពុទ្ធសករាជ ២៥៦១ ត្រូវនឹង ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៨ ជាមួយពិធីបញ្ចុះបឋមសិលាបើកការដ្ឋានសាងសង់ “អគារមជ្ឈមណ្ឌលពហុឯកទេស” ក្រោមអធិបតីភាព ឯកឧត្តម សាស្ត្រាចារ្យ ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ដែលនេះគឺជាយុទ្ធសាស្ត្រអភិវឌ្ឍន៍ដំណាក់កាលបន្តបន្ទាប់ នៃមន្ទីរពេទ្យកាល់ម៉ែត។

អគារទំនើបថ្មីមួយបន្ថែមទៀតនេះ នឹងបំពាក់នូវបច្ចេកវិទ្យាវេជ្ជសាស្ត្រឈានមុខ ដែលប្រមូលផ្តុំទៅដោយឯកទេសវេជ្ជសាស្ត្រ និងសល្យ សាស្ត្រសំខាន់ៗទាំងអស់រួមទាំង ផ្នែកសង្គ្រោះបន្ទាន់ ផ្នែកប្រពោធនកម្មពហុឯកទេសទំនើប។












ការអភិវឌ្ឍមជ្ឈមណ្ឌលពហុឯកទេសដែលនឹងផ្តល់ជូនសេវាសុខភាពគ្រប់ជំនាញ ត្រូវបានកំណត់មួយផ្នែក ដោយការកើនឡើងយ៉ាងលើសលប់ នៃអត្រាប្រើប្រាស់គ្រែ (១២៨% នៅឆ្នាំ២០១៧) និងមួយផ្នែកទៀត ដោយស្ថានភាពជំងឺកាន់តែធ្ងន់ធ្ងរ និងស្មុគស្មាញ ជាពិសេសក្នុង គោលដៅ សម្រាប់ដោះស្រាយគ្រប់បញ្ហាសុខភាព ប្រឈមចុងក្រោយ នៅព្រះរាជាណាចក្រកម្ពុជា។ អគារមជ្ឈមណ្ឌលពហុឯកទេសនេះក៏ជាមជ្ឈមណ្ឌលបណ្តុះបណ្តាល ធនធានមនុស្សកម្រិតឯកទេស និងស្រាវជ្រាវ ដែលជាត្រីវិស័យ ដើម្បីវិភាគ និងកំណត់គោលនយោបាយវិស័យមន្ទីរពេទ្យ សម្រាប់អនាគតកាន់តែ ប្រសើរជាលំដាប់។

ជំហានថ្មីបន្ទាប់ដើម្បីសម្រេចបាននូវអគារពហុឯកទេស ដែលមាន ទំហំ ៣២៨គ្រែ រួមទាំងឧបករណ៍វេជ្ជសាស្ត្រទំនើប គឺជាផ្លែផ្កាដែលបាន អំពីការជំរុញយ៉ាងយកចិត្តទុកដាក់ ដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខា ភិបាល និងទទួលបានការឯកភាពគាំទ្រយ៉ាងពេញទំហឹងប្រកបដោយ ការលើកទឹកចិត្តដ៏ថ្លៃថ្លាបំផុតពីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។









# “ស្ត្រីរួមគ្នារក្សាសន្តិភាព ដើម្បីអភិវឌ្ឍន៍ជាតិ”

# ៨មីនា

ព្រឹកថ្ងៃពុធ ៦រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៨ មន្ទីរពេទ្យកាល់ម៉ែត បានប្រារព្ធពិធីអបអរសាទរ ទិវាអន្តរជាតិនារី ៨មីនា ក្រោមប្រធានបទ "ស្ត្រីរួមគ្នារក្សាសន្តិភាព ដើម្បីអភិវឌ្ឍន៍ជាតិ "។

ការប្រារព្ធទិវានេះ ក្នុងគោលបំណងរំលឹកដល់ការតស៊ូរបស់នារីនៅទូទាំងសកលលោក ក្នុងការទាមទារឱ្យមានការលើកកម្ពស់សិទ្ធិ ស្ថានភាព ជីវភាព ឋានៈ តួនាទីរបស់ស្ត្រី មានការលើកឡើងនូវប្រធានបទដែលមានខ្លឹមសារស្របទៅនឹងបរិបទរបស់ប្រទេស ដែលជំរុញឱ្យមានការលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងគ្រប់វិស័យ ដើម្បីស្ត្រីបានចូលរួមចំណែកថែរក្សា ការពារសន្តិភាព សន្តិសុខ សុវត្ថិភាពសង្គម សេចក្តីសុខចម្រើន និងបង្កើនសេដ្ឋកិច្ចរបស់ក្រុមគ្រួសារ សហគមន៍ និងសង្គមជាតិ។







“មន្ទីរពេទ្យកាល់ម៉ែតសូមគោរពជូនពរស្ត្រីគ្រប់រូប សូមមានសុខភាពល្អ និងប្រាជ្ញាស្មារតីបរិបូរណ៍ដើម្បីចូលរួមចំណែកក្នុងកិច្ចអភិវឌ្ឍន៍គ្រួសារ ស្ថាប័ន និង សង្គមជាតិ។”







# តើជំងឺដុំមហារីកបំពង់អាហារ អាចមានរោគសញ្ញាអ្វីខ្លះ?

ជំងឺមហារីកបំពង់អាហារ គឺជាការវិវត្តមិនប្រក្រតី (លឿនខុសធម្មតា) នៃកោសិការបស់បំពង់អាហារ បង្កើតបានជាដុំសាច់ ដែលយើងតែងតែហៅថាជាជំងឺដុំសាច់មហារីក (cancer) នៃបំពង់អាហារ។ ជំងឺនេះត្រូវបានចែកជាពីរប្រភេទធំៗគឺ ពួកស្គេមមើសសែល ការស៊ីណូមម៉ា (sqamous cell carcinoma) និងអាដេណូកាស៊ីណូមម៉ា (adenocarcinoma) ។

**ក) តើជំងឺដុំមហារីកបំពង់អាហារ អាចមានរោគសញ្ញាអ្វីខ្លះ?**

យើងតែងតែសង្កេតឃើញថា អ្នកជំងឺដែលមានដុំមហារីកបំពង់អាហារនេះ គឺមានរោគសញ្ញាដូចជា៖

- អួលណែន និងពិបាកលេបអាហារចូល (ដំបូង អាហាររឹង បន្ទាប់មករាវ និងចុងក្រោយទឹកក៏ពិបាកលេបដែរ) ។
- ឈឺចុកចាប់ នៅពេលបរិភោគអាហារ
- ក្អួតចង្អោរ បន្ទាប់ពីបរិភោគអាហាររួច
- មានការចុកណែនអួល ក្នុងដើមទ្រូង
- មានការស្លេកស្លាំង និងខ្វះគ្រាប់ឈាមក្រហម
- ចុះខ្សោយ អស់កម្លាំង កំហែង និងល្ហិតល្ហៃ
- មិនចង់ទទួលទានអាហារ និងធុំសាច់
- ស្រកទម្ងន់ខ្លាំងខុសពីធម្មតា
- ពេលខ្លះវាក៏អាចបណ្តាលឲ្យមានការហូរធ្លាក់ឈាមផងដែរ។ល។

**ខ) តើមានមូលហេតុអ្វីខ្លះដែលអាចបណ្តាលឲ្យកើតមានឡើងនៃដុំមហារីកនេះ?**

កត្តាប្រឈមដែលអាចបង្កឲ្យមានដុំមហារីកនេះកើតមានបានមានដូចជា៖

- ការពិសាបារី រយៈពេលវែង
- ពិសាសុរាច្រើនហួសកម្រិត
- ជំងឺច្រាលជាតិអាស៊ីតរបស់ក្រពះ និងរលាកបំពង់អាហាររ៉ាំរ៉ៃដោយមិនបានព្យាបាលត្រឹមត្រូវតាមក្បួនច្បាប់វេជ្ជសាស្ត្រ (GERD)។
- អាយុច្រើន (លើសពី ៥៥ ឆ្នាំ)
- ភេទ ប្រុស
- ការទទួលទានចំណីអាហារមិនសមស្របៗល។

**គ) ការធ្វើរោគវិនិច្ឆ័យ៖** វិធីតែមួយគត់ដែលច្បាស់លាស់ ដើម្បីធ្វើរោគវិនិច្ឆ័យជំងឺមហារីកបំពង់អាហារនេះបាននោះគឺ ការថតឆ្លុះក្រពះ ព្រមទាំងធ្វើការយកសាច់ទៅវិភាគនៅមន្ទីរពិសោធន៍ (Gastric Fibroscopy and Anapath)។ បន្ទាប់ពីនោះក៏ត្រូវមានផងដែរគឺ ការថតស្កេន មើលដើមទ្រូង និងផ្ទៃពោះ (Thoraco-abdomonal CT-SCAN with injection) ដើម្បីកំណត់បាននៅដំណាក់កាល និងការវិវត្តន៍របស់ជំងឺ ហើយក៏ដើម្បីអនុញ្ញាតឲ្យក្រុមគ្រូពេទ្យ កំណត់ទៅលើការព្យាបាលផងដែរ។

**ឃ) ការព្យាបាល៖** ការព្យាបាលជំងឺដុំមហារីកបំពង់អាហារនេះ គឺត្រូវទាមទារឲ្យមានការចូលរួម ពីសំណាក់ក្រុមវេជ្ជបណ្ឌិតច្រើនមុខជំនាញ ដើម្បីធ្វើការពិភាក្សារិះរកវិធីមួយដែលល្អបំផុតសម្រាប់អ្នកជំងឺ ទើបការព្យាបាលអាចមានប្រសិទ្ធភាពខ្ពស់ និងចំគោលដៅ ក្នុងនោះមាន៖

- ក្រុមវេជ្ជបណ្ឌិតផ្នែក ថ្លើម ក្រពះ ពោះវៀន
- ក្រុមវេជ្ជបណ្ឌិតផ្នែកវះកាត់
- ក្រុមវេជ្ជបណ្ឌិតផ្នែក ជំងឺមហារីក
- និងក្រុមវេជ្ជបណ្ឌិតផ្នែករូបភាពវេជ្ជសាស្ត្រ ។
- សំខាន់ជាងនេះទៅទៀតក្រុមគ្រួសារអ្នកជំងឺនិងអ្នកជំងឺផ្ទាល់ក៏ត្រូវចូលរួមក្នុងការធ្វើការសម្រេចចិត្តផងដែរ ។ ជម្រើសជាច្រើននិងត្រូវបានលើកឡើងផលប្រយោជន៍ និង ផលវិបាក នៃជម្រើសនិមួយៗត្រូវបានពន្យល់និងធ្វើការពិភាក្សាជាមួយអ្នកជំងឺ និង ក្រុមគ្រោះសារ ។ ការសំរេចត្រូវតែមានការព្រមព្រៀងពី អ្នកជំងឺនិងក្រុមគ្រួសារ។

ទោះជាយ៉ាងណា ប្រសិទ្ធភាពនៃការព្យាបាលជំងឺមហារីកបំពង់អាហារគឺមានកម្រិត ដោយភាគច្រើននៃអ្នកជំងឺមកជួបពិគ្រោះជាមួយគ្រូពេទ្យគឺមានសភាពធ្ងន់ធ្ងរ ដែលជាហេតុនៃការយឺតយ៉ាវក្នុងការធ្វើរោគវិនិច្ឆ័យ (អ្នកជំងឺមកជួបគ្រូពេទ្យយឺតពេល) ។ ការព្យាបាលដែលមានប្រសិទ្ធភាពបំផុតគឺត្រូវធ្វើនូវដំណាក់កាលដំបូង ដែលអ្នកជំងឺមិនទាន់មានលេចចេញជារោគសញ្ញា ។ ការឆ្លុះក្រពះគឺជាវិធីសាស្ត្រតែមួយគត់ដែលអាចឲ្យយើងដោះស្រាយបញ្ហានេះបាន ។

សូមជួបជាមួយវេជ្ជបណ្ឌិតជំនាញនៃមន្ទីរពេទ្យកាល់ម៉ែត ដើម្បីធ្វើរោគវិនិច្ឆ័យ និងព្យាបាលជំងឺនេះឲ្យទាន់ពេលវេលា!






# ជំងឺគ្រោះថ្នាក់សរសៃឈាមខួរក្បាល អាចបង្ការបាន!



ជំងឺគ្រោះថ្នាក់សរសៃឈាមខួរក្បាល (Stroke) គឺជាមូលហេតុចម្បងទីមួយនៃពិការភាព នៅទូទាំងសកលលោក ជាពិសេសលើមនុស្សដែលមានអាយុលើសពី ៦៥ឆ្នាំឡើងទៅ។ ក្នុងរវាងកន្លះសតវត្សចុងក្រោយនេះ អត្រានៃជំងឺនេះមានការថយចុះប្រហែល 40ភាគរយនៅប្រទេសអភិវឌ្ឍន៍ តែមានការកើនឡើង ១០០ភាគរយ នៅបណ្តាប្រទេស ដែលមានចំនូលទាប និងមធ្យម។

ដោយសារតែជំងឺនេះ ភាគច្រើន អាចមានសភាពធ្ងន់ធ្ងរ បណ្តាលឲ្យស្លាប់ ឬក៏បន្សល់នូវភាពពិការច្រើន ទោះបី បច្ចុប្បន្ននេះមានការព្យាបាលដោយបច្ចេកវិទ្យាទំនើបៗក៏ដោយ ទើបមានការសិក្សាស្រាវជ្រាវជាច្រើន ដើម្បីស្វែងរកវិធីបង្ការកុំឲ្យកើតមានជំងឺនេះ។
កត្តាដែលអាចបង្ការជំងឺគ្រោះថ្នាក់សរសៃឈាមខួរក្បាល ដែលយើងគ្រប់គ្នាអាចអនុវត្តន៍បានគឺ ការផ្លាស់ប្តូរទម្លាប់មួយចំនួនក្នុងជិវិតរស់ នៅប្រចាំថ្ងៃរបស់យើង (Lifestyle change)។

**ក) របបអាហារដែលយើងទទួលទានរាល់ថ្ងៃ៖**

- ត្រូវពិសាអាហារដែលមានជាតិអំបិលតិចបំផុត
- ពិសាបន្លែ និងផ្លែឈើឲ្យបានច្រើនមុខ
- ត្រូវបញ្ចូលគ្រាប់ធញ្ញជាតិទៅក្នុងរបបអាហារប្រចាំថ្ងៃរបស់យើង។

វាមានសារៈសំខាន់ណាស់ក្នុងការកាត់បន្ថយជំងឺ Stoke នេះ ដោយការទទួលទានអាហារសុខភាព(Healthy diet) អាចកាត់បន្ថយហានិភ័យនេះបានដោយតាមរយៈ ការការពារជំងឺមួយចំនួនដូចជា:

- ជំងឺលើសឈាម
- ជំងឺទឹកនោមផ្អែម
- លើសជាតិខ្លាញ់
- ជំងឺធាត់
- និងជំងឺសរសៃឈាមបេះដូងជាដើម។ល។



**ខ) តើត្រូវធ្វើលំហាត់ប្រាណបែបណា ទើបគ្រប់គ្រាន់និងត្រឹមត្រូវ?**

ការធ្វើលំហាត់ប្រាណ គឺអាចកាត់បន្ថយជំងឺលើសឈាម និងមូលហេតុបង្កផ្សេងៗទៀត នៃជំងឺសរសៃឈាម។ យើងត្រូវធ្វើលំហាត់ប្រាណឲ្យបានយ៉ាងតិច ៣ ទៅ ៤ដងក្នុងមួយសប្តាហ៍ និងម្តងៗមានរយៈពេលយ៉ាងតិច ៣០នាទី។



**គ) កត្តាផ្សេងៗទៀត ដែលយើងត្រូវយកចិត្តទុកដាក់មានដូចជា៖**

- ត្រូវរក្សាលំនឹងទម្ងន់ឲ្យបានសមស្រប
  - បុរស: រង្វង់ចង្កេះកុំឲ្យលើសពី ៩០ សង់ទីម៉ែត
  - នារី: រង្វង់ចង្កេះកុំឲ្យលើសពី ៨០ សង់ទីម៉ែត
  - BMI: សូមឲ្យតិចជាង ២៣គីឡូក្នុងមួយម៉ែតការ៉េ (< 23 Kg/m2)
- ត្រូវអញ្ជើញពិនិត្យ និងព្យាបាល ជំងឺលើសឈាម ជំងឺទឹកនោមផ្អែម លើសជាតិខ្លាញ់ និងជំងឺបេះដូងនិងសរសៃឈាមឲ្យបានត្រឹមត្រូវ។

សរុបសេចក្តីមក ដើម្បីជៀសវាងពីជំងឺកាចសាហាវនេះ យើងទាំងអស់គ្នា គប្បីថែរក្សាសុខភាពយើងឲ្យបានល្អ និងត្រូវធ្វើការពិនិត្យសុខភាពឲ្យបានទៀងទាត់ជាមួយនិងក្រុមវេជ្ជបណ្ឌិតជំនាញនៃមន្ទីរពេទ្យកាល់ម៉ែត។

"សូមចូលរួមទាំងអស់ ដើម្បីកាត់បន្ថយជំងឺគ្រោះថ្នាក់សរសៃឈាមខួរក្បាល ពីព្រោះពិការភាព នាំឲ្យខាតបង់ធំធេងណាស់ ចំពោះជីវិតយើង គ្រួសារយើង និង សង្គមជាតិយើង។"

# ជំងឺលើសឈាម
# ឬជំងឺលើសសម្ពាធឈាម!



ជំងឺលើសឈាម ឬជំងឺលើសសម្ពាធឈាម គឺជា ការកើនឡើងនៃសម្ពាធឈាម លើសពី កម្រិតធម្មតា (ដឹងបានតាមរយៈម៉ាស៊ីនវាស់សម្ពាធឈាម) ដែលវាអាចផ្តល់ផលប៉ះពាល់ទៅលើជញ្ជាំងសរសៃឈាមនៃសរីរាង្គផ្សេងៗ ជាពិសេសសរសៃឈាមបេះដូង និងសរសៃឈាមខួរក្បាល។ ជំងឺលើសឈាម ត្រូវបានទទួល ស្គាល់ថាជាឃាតករសំងាត់ ដែលអាចសម្លាប់យើងបានគ្រប់ពេលវេលា។

**ក) រោគសញ្ញា៖**

ជាទូទៅ មនុស្សភាគច្រើនដែលកើត ជំងឺលើសឈាមមិនមានស្តែងចេញជារោគសញ្ញាផ្សេងៗទេ បើទោះបីជាសម្ពាធឈាមឡើងខ្ពស់ដល់ កម្រិតធ្ងន់ធ្ងរដែលអាចប៉ះពាល់ដល់អាយុជីវិតក៏ដោយ។ ការដែលមិនមានរោគសញ្ញានេះ ទើបធ្វើឲ្យគេហៅជំងឺលើសឈាមថា ឃាតករសំងាត់។ ក៏ប៉ុន្តែ មានអ្នកជំងឺលើសឈាមមួយចំនួនតូចអាចមានរោគសញ្ញាដូចជា:

- ឈឺក្បាល
- រោយកញ្ចឹងក
- វិលមុខ
- ស្រវាំងភ្នែក
- ឈាមច្រមុះ ជាដើម។

**ចំណាត់ថ្នាក់កម្រិតសម្ពាធឈាម៖**

- សម្ពាធឈាមធម្មតា សម្ពាធអតិបរមាតិចជាង 120 mmHg និងសម្ពាធអប្បបរមាតិចជាង 80 mmHg
- សម្ពាធឈាមមុនលើសឈាម សម្ពាធអតិបរមា120-139 mmHg និងសម្ពាធអប្បបរមា 80-89mmHg
- លើសសម្ពាធឈាមដំនាក់កាលទី1 សម្ពាធអតិបរមា140-159 mmHg និងសម្ពាធអប្បបរមា90-99mmHg
- លើសសម្ពាធឈាមដំនាក់កាលទី2 សម្ពាធអតិបរមាធំជាងឬលើស160 mmHg និង សម្ពាធអប្បបរមាធំជាងឬលើស100 mmHg

**ខ) មូលហេតុអ្វីខ្លះដែលបណ្តាលឲ្យកើតជំងឺលើសឈាម៖**

តាមការសិក្សាបានបញ្ជាក់ ៩០-៩៥% នៃជំងឺលើសឈាម គឺមិនមាន មូលហេតុពិតប្រាកដឡើយ។ ចំណែក ១០-១៥% នៃជំងឺលើសឈាមអាចមាន មូលហេតុច្បាស់លាស់ដែលមានដូចខាងក្រោម៖

- ជំងឺតម្រងនោម (Kidney problems)
- ជំងឺក្រពេញក (Thyroid problems)
- ជំងឺក្រពេញលើក្រពេញតំរងនោម (Adrenal gland problems)
- ជំងឺពិបាកចិត្ត (stress)
- ពិសាគ្រឿងស្រវឹង(Alcohol abuse or chronic alcohol use)
- ប្រើប្រាស់គ្រឿងញៀន (cocaine និង amphetamines)

**គ) កត្តាប្រឈមមុខ ដែលជំរុញឲ្យកើតជំងឺលើសឈាម៖**

- អាយុច្រើន(បុរសលើសពី៥៥ឆ្នាំ ស្ត្រីលើសពី៦៥ឆ្នាំ)
- មិនសូវ ឬមិនបានហាត់ប្រាណ
- ជក់បារី
- ជំងឺទឹកនោមផ្អែម
- លើសទម្ងន់ ធាត់
- លើសជាតិខ្លាញ់
- មានប្រវត្តិ ឬកំពុងប្រើប្រាស់ថ្នាំដែលនាំឲ្យលើសឈាម
- ប្រវត្តិក្រុមគ្រួសារមានជំងឺសរសៃឈាមបេះដូង ជំងឺទឹកនោមផ្អែម និង ជំងឺលើសឈាម។

**ឃ) ជំងឺលើសឈាមផ្តល់ផលវិបាក ដល់សុខភាព៖**

ការកើនឡើងនៃសម្ពាធឈាមលើសពីកម្រិតធម្មតា អាចធ្វើឲ្យប៉ះពាល់ដល់ជញ្ជាំងសរសៃឈាម និងសរីរាង្គផ្សេងៗ។ កាលបើសម្ពាធឈាមកាន់តែខ្ពស់ និងមិនបានព្យាបាលត្រឹមត្រូវកាន់តែយូរ ផលវិបាក និងហានិភ័យដល់សុខភាពកាន់ តែមានច្រើនឡើងៗ។

អ្នកជំងឺលើសឈាមដែលមិនបានទទួលការព្យាបាលត្រឹមត្រូវ អាចប្រឈមនឹងផលវិបាកដល់សុខភាព ដូចជា៖

- ជំងឺស្ទះសរសៃឈាមបេះដូង ឬជំងឺស្ទះដាច់សរសៃឈាមខួរក្បាល
- ជំងឺគាំងបេះដូង - ជំងឺខ្សោយបេះដូង - ជំងឺខ្សោយតំរងនោម
- ជំងឺងងឹតភ្នែក - ជំងឺក្រឡាភ្លើងចំពោះស្ត្រីមានផ្ទៃពោះ។

**ង) វិធានការអ្វីខ្លះដើម្បីបង្ការជំងឺលើសឈាម៖**

- បញ្ចុះទម្ងន់ និងរក្សាទម្ងន់ឲ្យត្រឹមត្រូវតាមស្តង់ដារ
- ហូបអាហារណាដែលផ្តល់ផលល្អដល់សុខភាពមានដូចជា បន្លែ ផ្លែឈើ បាយ អង្ករសំរោប អាហារដែលសំបូរ ជាតិប៉ូតាស្យូមជាពិសេសផ្លែចេកណាំវ៉ា ផ្កាខាត់ណា ផ្លែប័រ និងគ្រាប់ធុញ្ញជាតិជាដើម។
- តមការហូបប្រៃ - បន្ថយការហូបជាតិខ្លាញ់ និងប្រេង
- ឈប់ពិសាបារី និងគ្រឿងស្រវឹង - បន្ថយបញ្ហាពិបាកចិត្ត គិតច្រើន
- ធ្វើលំហាត់ប្រាណយ៉ាងហោចណាស់ឲ្យបាន៣០នាទីរៀងរាល់ថ្ងៃ។

**ច) ការព្យាបាលជំងឺលើសឈាម៖**

មកដល់សព្វថ្ងៃនេះ ជំងឺលើសឈាម មិនទាន់អាចព្យាបាលឲ្យជាសះស្បើយ បាននៅឡើយទេ។ ប៉ុន្តែ ការព្យាបាលដោយថ្នាំ អាចធ្វើឲ្យសម្ពាធឈាម ធ្លាក់មកស្ថិតនៅក្នុងកម្រិតធម្មតាវិញ ជៀសផុតពី ផលវិបាក និងហានិភ័យផ្សេងៗដែលបណ្តាលមកពីជំងឺលើសឈាម។



# ស្វែងយល់ពីប្រភេទជំងឺសើស្បែកមួយចំនួន
# ដែលកើតលើក្មេងតូចៗ!



យើងតែងតែរំពឹងថា ស្បែកកូនក្មេងជាស្បែកផូរផង់រលោងហ្មត់ ប៉ុន្តែជាញឹកញាប់ក្មេងងាយប្រឈមនឹងបញ្ហាស្បែកដូចមនុស្សធំដែរ ដោយសារស្បែកគឺជាសរីរាង្គដែលប្រឈមដោយផ្ទាល់ជាមួយបរិស្ថាន។ ជំងឺស្បែកមួយចំនួនធំដែលកើតលើក្មេងតូចតែស្រួចស្រាវ ហើយជារឿយៗ អាចជាដោយខ្លួនឯងដោយមិនបន្សល់ទុកនូវស្លាកស្នាមអ្វីទាំងអស់។ សូមងាកមកស្វែងយល់ពីជំងឺស្បែកមួយចំនួនដែលកើតលើក្មេងតូច ដូចខាងក្រោមនេះ៖

- Vernix caseosa : កំអែលខ្លាញ់ស្អិតពណ៌ស ឬ ពណ៌ប្រផេះ អាចមាននៅលើស្បែកក្មេងដែលទើបកើត ដែលមានតួនាទីចូលរួមការពារទារកប្រឈមនឹងបរិស្ថានជុំវិញ។ ស្ថានភាពស្បែកនេះនឹងវិលមករកភាពធម្មតាដោយខ្លួនឯង។



- Sebaceous hyperplasia: ការរីកត្រដែតនៃក្រពេញខ្លាញ់ នៅលើច្រមុះ ថ្ពាល់ ពុកមាត់ និង ថ្ងាស សង្កេតឃើញភាគច្រើននៅលើក្មេងដែលកើតគ្រប់ខែ កើតឡើងដោយសាររងឥទ្ធិពលអរម៉ូន androgen ពីម្តាយ។ ស្ថានភាពនេះនឹងបាត់ទៅវិញដោយឯកឯង។



- Milium (plural Milia): កន្ទួលតូចៗពណ៌ស រឹង នៅលើមុខ ខ្លួន ដៃ ជើង ប្រដាប់ភេទ និង ក្នុងមាត់ អាចមាននៅលើស្បែកក្មេងដែលទើបកើត ហើយអាចបាត់ទៅវិញដោយឯកឯង ឬ ករណីខ្លះត្រូវឆ្កឹះយកចេញដោយបច្ចេកវិជ្ជាពេទ្យ។



- Miliaria: កន្ទួលពងទឹកតូចៗ ថ្លា ឬ ក្រហមឈ្យូកលាយជាមួយខ្ទុះ បណ្តាលមកពីសីតុណ្ហភាពក្តៅ នាំឲ្យកកស្ទះរន្ធញើស។ ករណីនេះសង្កេតឃើញនៅថ្ងាស ក ខ្លួន និង កន្លែងហប់។ ស្ថានភាពនេះអាចបាត់ទៅវិញដោយស្លៀកសំលៀកបំពាក់ត្រជាក់ និង បន្ថយសីតុណ្ហភាពកន្លែងនៅឲត្រជាក់ល្មម។



- Toxic erythema of newborn: ស្ថានភាពនេះកើតឡើងលើក្មេងតូចដែលកើតមិនគ្រប់ខែ ឬ ទម្ងន់តិចជាង ២៥០០ក្រាម។ ស្តែងឡើងជា កន្ទួលស្បែកក្រហម អាចលាយឡំជាមួយកន្ទួលខ្ទុះពណ៌លឿងនៅ មុខ ខ្លួន ដៃជើង លើកលែងបាតដៃបាតជើង។ កើតឡើងដោយមូលហេតុមិនច្បាស់លាស់ ហើយកើតនៅថ្ងៃទី២នៃថ្ងៃចាប់កំណើត នឹងបាត់ទៅវិញបន្ទាប់ពី១ទៅ៤អាទិត្យ។



- Pityriasis alba: ភាគច្រើនកើតលើក្មេងតូចដែលមានជំងឺ atopic dermatitis ស្តែងចេញជាបន្ទះសជាមួយក្រមរស្តើង ភាគច្រើនសង្កេតឃើញនៅមុខ ជាពិសេសថ្ពាល់។ ជំងឺនេះអាចជាដោយមិនបាច់ព្យាបាល ឬ ជៀសវាងបានដោយជៀសកម្តៅថ្ងៃ។ បើករណីធ្ងន់ moisturizing cream និង topical steroid អាចសម្រាលរោគសញ្ញាបាន។

- Molluscum contagiosum: បង្កដោយ poxvirus (molluscum contagiosum virus) សង្កេតឃើញកើតលើក្មេងក្រោមអាយុ១០ឆ្នាំ រស់នៅតំបន់អាកាសធាតុក្តៅ ឆ្លងដោយការប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលតាមរយៈរបស់ប្រើប្រាស់រួម។ ជាកន្ទួលរឹងមានចំណុចផតកណ្តាល ពណ៌ដូចស្បែក ឬ ក្រហមឈ្យូក។ ព្យាបាលដោយ curettage តាមបច្ចេកទេសពេទ្យបានដោយមានប្រសិទ្ធិភាពដើម្បីបន្ថយការចម្លងរីករាលដាលនៃជម្ងឺ។



ដូច្នេះ បើលោកអ្នកមានកូនឬក្មួយដែលមានបញ្ហាស្បែក សូមអញ្ជើញមកពិគ្រោះ និងទទួលយកការព្យាបាលជាមួយគ្រូពេទ្យជំនាញសើស្បែកនៅមន្ទីរពេទ្យកាល់ម៉ែត ដែលនឹងផ្តល់ការព្យាបាលត្រឹមត្រូវតាមបច្ចេកវិជ្ជាពេទ្យ ។

# បងប្អូនស្ត្រីព្រួយបារម្ភណ៍ ពីគីសដៃស្បូន !




តាមពិតទៅ ដុំគីសដៃស្បូន ជាដុំទឹកស្រោបដោយស្រោមនៅក្នុង ឬនៅលើផ្ទៃនៃអូវែ ដែលនៅសងខាងស្បូនស្ត្រី។

**ក) រោគសញ្ញា៖**

- ឈឺអាងត្រគាកស្ទំៗ និងអាចរាលដាលទៅក្រោយ
- ឈឺអាងត្រគាកមុនចាប់ផ្តើមមករដូវ ឬពេលរួមដំណេក (Dyspareunia)
- ក្អួតចង្អោរ និងមានអារម្មណ៍ថាពេញណែនធ្ងន់ក្នុងពោះ
- នោមញឹក ឬក៏ពិបាកនោម
- អាចមានចុកពោះខ្លាំងភ្លាមៗ ព្រមទាំងក្អួត និងក្តៅខ្លួន
- ភាគច្រើនវាវិវត្តន៍ធំធាត់ដោយស្ងៀមស្ងាត់

**ខ) មូលហេតុ៖**

មូលហេតុនៃជំងឺនេះ កើតឡើងទៅតាមប្រភេទនៃគីសនីមួយៗ:

១. Follicular cyst: ដោយវាពុំបានបញ្ចេញពងមេជីវិត។

២. Corpus luteum cyst: ពងមេជីវិតត្រូវបានបញ្ចេញ ប៉ុន្តែរន្ធនោះត្រូវបានបិទជិតវិញ។ ដុំគីសទាំងពីរប្រភេទនេះ (១ និង២)មិនមានបញ្ហាអ្វីទេ វានឹងបាត់ទៅវិញក្នុងរយៈ ពេល ២ ទៅ ៣ខែ បន្ទាប់។

៣. Dermoidcysts: ផ្សំទៅដោយជាលិកាផ្សេងៗដូចជា សក់ ស្បែក ឬក៏ធ្មេញ...។ ករណីនេះកម្រក្លាយជាមហារីកណាស់។

៤. Cystadenomas: ផ្សំដោយទឹករំអិលខាប់ៗ ដែលកើតចេញពីជាលិកាអូវែ

៥. Endometriomas: ផ្សំដោយឈាមរដូវខាប់ៗដែលកើតចេញពីកោសិការ អង់ដូម៉ែត និង រីកធំធាត់នៅក្រៅស្បូន។

**គ) ផលវិបាក៖**

- ដុំគីសដែលកើតលើស្ត្រីចំណាស់ក្រោយពេលអស់រដូវអាចក្លាយជាមហារីក។
- Ovarian Torsion គឺដុំគីសដែលរមួលបណ្តាលឲ្យចុកពោះខ្លាំង។
- Ovarian Rupture គឺដុំគីសដែលបែករហែកបណ្តាលឲ្យចុកពោះខ្លាំងនិងមាន ឈាមដក់ក្នុងពោះ។

**ឃ) ការព្យាបាល៖**

ការព្យាបាលគឺអាស្រ័យទៅតាម រោគសញ្ញា អាយុស្ត្រី ប្រភេទ និងទំហំគីសៈ

- ករណីធម្មតា (ប្រភទដុំគីស Follicular cyst និង Corpus luteum cyst): អ្នកជំងឺមិនតម្រូវឲ្យមានការវះកាត់ទេ។
- ករណីធ្ងន់ធ្ងរ គឺតម្រូវឲ្យធ្វើការវះកាត់:
  - ■ ការវះកាត់ដោយបើកពោះ (Laparotomie)
  - ■ ការវះកាត់ដោយប្រើឧបករណ៍ចោះ (Laparoscopic): ការវះកាត់ដោយមានស្នាមរបួសតូច មិនសូវមានការឈឺចាប់ និងអាចបានត្រឡប់ទៅផ្ទះឆាប់រហ័ស។

ការវះកាត់ទាំងពីរនេះមានប្រយោជន៍សំខាន់ដល់ស្ត្រី ដោយរក្សាទុកដៃស្បូន ជាពិសេសស្ត្រីដែលនៅវ័យក្មេង អាចឲ្យមានបុត្រទៅថ្ងៃក្រោយ។










បើសិនជាមានបញ្ហាដូចរៀបរាប់ខាងលើ សូមអញ្ជើញមកមន្ទីរពេទ្យកាល់ម៉ែត ដែលមានគ្រូពេទ្យជំនាញឯកទេស និងមធ្យោបាយគ្រប់គ្រាន់ ក្នុងការធ្វើរោគវិនិច្ឆ័យ និងកំណត់ប្រភេទគីសឲ្យបានត្រឹមត្រូវ ដើម្បីទទួលបានការព្យាបាលសមស្រប។

# សំណួរចម្លើយ Quiz?

# ទាក់ទងនឹងសុខភាព



## Q1. តើជំងឺរបេង មានរោគសញ្ញាដូចម្ដេច?

១. ហៀរសំបោរ

២. ក្អក

៣. ឈឺក



## Q2. តើទារកគ្រប់ខែ មានទំងន់ប៉ុន្មានគីឡូក្រាម ដែលគិតថាត្រឹមត្រូវ សមស្របល្អ?

១. ចន្លោះពី ១,៥kg ទៅ ២,៥kg

២. ចន្លោះពី ២,៥kg ទៅ ៣,៥kg

៣. ចន្លោះពី ៣,៥kg ទៅ ៤,៥kg




## Q3. ជំងឺរលាកលំពែង បណ្ដាលមកពីអ្វី?

១. ការពិសារស្រាយូរៗម្ដងតែមានបរិមាណច្រើន

២. ការពិសារស្រាបន្តិចបន្តួចពេលបាយ

៣. ការពិសារស្រាជាប្រចាំរយៈពេលយូរ

## Q3. ដើម្បីសុវត្ថិភាព និងសុខភាពល្អ តើអ្នកជំងឺទឹកនោមផ្អែមអាចញ៉ាំកាហ្វេបានប៉ុន្មានពែងក្នុងមួយថ្ងៃ?

១. មួយពែង

២. ពីរពែង

៣. បីពែង

៤. លើសពីបីពែង





សូមមេត្តាផ្ទៀងផ្ទាត់ចម្លើយដែលផ្ដល់ជូននៅព្រឹត្តិបត្រលេខបន្ទាប់




# ទើបតែបាន ៤,៣គីឡូក្រាម វះកាត់បេះដូងដោយជោគជ័យ!

កុមារ “**ម៉ន ធីម**” កើតនៅខែកក្កដា ឆ្នាំ២០១៦។ តាំងពីចាប់កំណើតមក កុមារចំណាយពេលជាច្រើននៅគ្លីនិក និងមន្ទីរពេទ្យកុមារ។ កុមារមានប្រហោងថតក្រោម បេះដូងធ្ងន់ធ្ងរ និងត្រូវធ្វើការវះកាត់ជាបន្ទាន់ ពីព្រោះតាមការវិវត្តន៍ពីធម្មជាតិរបស់ជំងឺនេះ អាចឲ្យ ម៉ន ធីម ប្រឈមមុខនឹងការហួសពេលវះកាត់ក្នុងពេលឆាប់ៗ ខាងមុខ។

ក្រោមកិច្ចសហប្រតិបត្តិការរវាងក្រុមគ្រូពេទ្យឯកទេសបេះដូង មកពីសកលវិទ្យាល័យ MOTOL UNIVERSITY នៃសាធារណរដ្ឋឆែក និងក្រុមគ្រូពេទ្យឯកទេស បេះដូងនៃមន្ទីពេទ្យកាល់ម៉ែត ម៉ន ធីម ត្រូវបានធ្វើការវះកាត់សង្គ្រោះជីវិត។

ជាលទ្ធផល ការពិនិត្យនិងអេកូបេះដូងក្រោយការវះកាត់ បានបញ្ជាក់ថាកុមារបានជាសះស្បើយទាំងស្រុង ពោលគឺគ្មានប្រហោងបេះដូងទៀតទេ។
ក្រុមគ្រួសារព្រមទាំងក្រុមការងារនៃផ្នែកបេះដូងមន្ទីរពេទ្យកាល់ម៉ែត មានការត្រេកអរឥតឧបមា។







ព្រឹត្តិបត្រសុខភាពមន្ទីរពេទ្យកាល់ម៉ែត
ព្រឹត្តិបត្រសុខភាពមន្ទីរពេទ្យកាល់ម៉ែត



## ឧបត្ថម្ភដោយ

Expertise for the Promotion of Health

លេខ ៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: ០១១ ៤១ ៤០ ៦៥, ០៧៧ ៣៦ ១៧ ៥១, ០១៧ ៨៦ ៦៨ ៤៧
អ៊ីម៉ែល: hospital@calmette.gov.kh, វេបសាយ: www.calmette.gov.kh
ហ្វេសប៊ុក: www.facebook.com/calmette.gov.kh